**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍**
លេខ...១៥៥......បទ..ប្រក............

# ប្រ កា ស
## ស្តី ពី
## ការបង្កើតការិយាល័យសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ នៃនាយកដ្ឋានផែនការ និងហិរញ្ញវត្ថុ

## រដ្ឋមន្ត្រី ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ/បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ/បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៣ ស្តីពីការដំឡើងនាយកដ្ឋានរដ្ឋបាល និងបណ្តុះបណ្តាល ទៅជាអគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ១៨១ អនក្រ/បក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការដំឡើងអធិការដ្ឋានទៅជាអគ្គាធិការដ្ឋាននៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ/បក ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៦ ស្តីពីការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញការងារចាំបាច់របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

## <u>ស ម្រេ ច</u>

**ប្រការ១** .-

ត្រូវបានបង្កើតការិយាល័យសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ នៃនាយកដ្ឋានផែនការ និងហិរញ្ញវត្ថុនៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដែលមានប្រធានការិយាល័យមួយរូប និងអនុប្រធានការិយាល័យមួយចំនួនជាជំនួយការតាមការចាំបាច់។

**ប្រការ២**.-

ការិយាល័យសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ មានតួនាទីជាសេនាធិការ ឱ្យថ្នាក់ដឹកនាំនាយកដ្ឋាន ដែលមានភារកិច្ចដូចខាងក្រោម៖

១- ណែនាំ និងតាមដានការអនុវត្តជាប្រចាំរៀងរាល់ដើមឆ្នាំ (ត្រីមាសទី១) ឱ្យរដ្ឋបាលថ្នាក់កណ្តាល និងគ្រប់មន្ទីរ ប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តក្រោមឱវាទក្រសួងមាន៖

ក- ការគោរពតាមកាលកំណត់នៃថ្ងៃប្រគល់បញ្ជីសារពើភ័ណ្ឌ ឬតារាងប្រៀបធៀបទ្រព្យសម្បត្តិរដ្ឋកើនឡើង ថយចុះប្រចាំឆ្នាំនីមួយៗ មកនាយកដ្ឋានផែនការ និងហិរញ្ញវត្ថុ ដើម្បីធ្វើការបូកសរុបរាយការណ៍ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានទាន់ពេលវេលា។

ខ- ពិនិត្យ និងណែនាំជាពិសេសសំដៅមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្ត លើការយកចិត្តទុកដាក់ធ្វើប័ណ្ណកម្មសិទ្ធិទ្រព្យសម្បត្តិរដ្ឋ (ដីធ្លី អគារ)។

គ- ណែនាំក្នុងការអនុវត្តនីតិវិធីកត់ត្រាឱ្យបានច្បាស់នូវសកម្មភាពសម្ភារៈ៖

- រាល់ការកើនឡើងយានយន្ត ត្រូវធ្វើការកត់ត្រាដោយមានលក្ខណៈគ្រប់គ្រាន់ ថ្ងៃ ខែ ឆ្នាំផលិត លេខតួ លេខម៉ាស៊ីន ស្លាកលេខ និងប្រភពផ្តល់។
- រាល់ការកើនឡើងសម្ភារៈ និងសង្ហារឹមត្រូវធ្វើការកត់ត្រាពីបរិមាណ ថ្ងៃ ខែ ឆ្នាំប្រើប្រាស់ តម្លៃ ស្ថានភាព និងប្រភពផ្តល់។
- រាល់ការថយចុះនូវចលនទ្រព្យ និងអចលនទ្រព្យ ត្រូវភ្ជាប់ឯកសារច្បាស់លាស់ទៅតាមប្រភេទ និងតាមនីតិវិធី។

២-ណែនាំពីការចលនានូវចលនទ្រព្យផ្ទៃក្នុង ត្រូវមានឯកសារផ្ទេរច្បាស់លាស់ ជៀសវាងការបាត់បង់។

៣-រៀបចំផែនការចុះពិនិត្យ ណែនាំជួយដល់បណ្តាមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្ត ដើម្បីរៀបចំអនុវត្តការងារសារពើភ័ណ្ឌ ឱ្យបានសមស្រប ត្រឹមត្រូវ និងទាន់ពេលវេលា តាមសារាចរណែនាំលេខ០០១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

៤-រៀបចំ ចងក្រងសៀវភៅបញ្ជីសារពើភ័ណ្ឌ ឬតារាងប្រៀបធៀបទ្រព្យសម្បត្តិរដ្ឋកើនឡើង ថយចុះប្រចាំឆ្នាំ (នាសូន្យម៉ោងដំណាច់ឆ្នាំនីមួយៗ) ឱ្យបានត្រឹមត្រូវ ច្បាស់លាស់ ដើម្បីរាយការណ៍ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ៣**.-

ខុទ្ទកាល័យ អគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានប្រៃសណីយ៍និងទូរគមនាគមន៍ អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន គ្រប់មន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្ត ព្រមទាំងនាយកដ្ឋានផែនការ និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ៦ ឆ្នាំ២០១៣

**រដ្ឋមន្ត្រី**

ប្រាក់ សុខុន

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់
  "ដើម្បីជូនជ្រាប"
- ដូចប្រការ៣ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ